# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១០ វេលាម៉ោង ៩:០០ ព្រឹក នៅសាលប្រជុំនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានប្រារព្ធកិច្ចប្រជុំទ្វេភាគីរវាងរដ្ឋបាលគយកម្ពុជា ដឹកនាំដោយ ឯ.ឧ. បណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា និងរដ្ឋបាលគយកូរ៉េ ដឹកនាំដោយលោក **យ៉ាំង ស៊ុន យូន** អគ្គស្នងការនៃរដ្ឋបាលគយកូរ៉េ ក្នុងគោលបំណងពិភាក្សាគ្នាលើកិច្ចសហប្រតិបត្តិការលើវិស័យគយជាពិសេសកិច្ចសម្រួលពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។ កិច្ចប្រជុំនេះ គឺជាផ្នែកមួយនៃដំណើរទស្សនកិច្ចជាផ្លូវការលើកទី ១ របស់គណៈប្រតិភូគយកូរ៉េ រយៈពេល ៣ ថ្ងៃ មកកាន់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាមកកាន់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែរ ។

នៅក្នុងកិច្ចប្រជុំនេះ បន្ទាប់ពីបានលើកឡើងអំពីវឌ្ឍនភាព និងសមិទ្ធផលសម្រេចបាននាពេលថ្មីៗនេះរបស់អង្គភាពរៀងខ្លួនមក និងដោយយល់ថាទំហំវិនិយោគទុនរបស់កូរ៉េនៅកម្ពុជា និងការផ្លាស់ប្តូរទំនិញរវាងប្រទេសទាំងពីរកាន់តែកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃនោះ ភាគីទាំងពីរបានចុះហត្ថលេខា និងព្រមព្រៀងគ្នាដូចតទៅ ៖

១. បន្តពង្រឹងថែមទៀតនូវចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ និងឈានទៅបង្កើតអនុស្សារណៈនៃការយោគយល់គ្នារវាងរដ្ឋបាលគយទាំងពីរ ស្តីពីការជួយគ្នាទៅវិញទៅមក ។

២. បន្តកែលម្អយន្តការនៃការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ស្តីពីនីតិវិធីគយ ទំនើបកម្មអង្គភាព ព័ត៌មានស៊ើបការណ៍ និងទិន្នន័យស្ថិតិពាណិជ្ជកម្ម ។

៣. តាមការស្នើសុំរបស់ភាគីគយកម្ពុជា ភាគីគយកូរ៉េនឹងធ្វើការស្រាវជ្រាវ និងចាត់វិធានការចាំបាច់លើមុខសញ្ញាល្មើស ពាក់ព័ន្ធនឹងការនាំទំនិញពីប្រទេសកូរ៉េ មកព្រះរាជាណាចក្រកម្ពុជា ។

៤. ដើម្បីបង្កើនការសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយបាតុភាពអសកម្មនានាពាក់ព័ន្ធនឹងបែបបទបញ្ចេញទំនិញពីគយ ភាគីគយកម្ពុជាបានគូសបញ្ជាក់ថា នឹងប្រើប្រាស់នូវយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដែលមានស្រាប់ដើម្បីដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងគយនានា រួមទាំងបញ្ហារបស់ក្រុមហ៊ុនកូរ៉េនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ ។

៥. កិច្ចប្រជុំទ្វេភាគីលើកទី ២ នឹងប្រព្រឹត្តទៅក្នុងពេលអនាគតដ៏ខ្លី នៅប្រទេសកូរ៉េ ។

កិច្ចប្រជុំទ្វេភាគីលើកទី ១ នេះ បានបញ្ចប់នាម៉ោង ១១:០០ ព្រឹក ថ្ងៃដដែល ក្រោមបរិយាកាសមិត្តភាព រីករាយ និងស្និទ្ធស្នាលក្រៃលែង ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១០